**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងផែនការ**

# កំណត់ហេតុ

# កិច្ចប្រជុំគណៈកម្មាធិការសំរបសំរួលស្ថិតិលើកទី១

ឆ្នាំ ២០០៧ ខែ កុម្ភៈ ថ្ងៃទី ១៥ វេលាម៉ោង ៨:៣០ នាទីព្រឹកនៅសាលប្រជុំវិទ្យាស្ថានជាតិស្ថិតិមានបើកអង្គប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិ ក្រោមអធិបតីភាព ឯកឧត្តម **សន ស៊ីថន** អគ្គនាយកវិទ្យាស្ថាន ជាតិស្ថិតិ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលស្ថិតិ ដោយមានការចូលរួមពីមន្រ្តីជាសមាជិក ចំនួន២៧ក្រសួង ដូចមានរាយនាមខាងក្រោម :

១- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

២- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

៣-ក្រសួង អភិវឌ្ឍន៍ជនបទ

៤- ក្រសួង មហាផ្ទៃ

៥- ទីស្តីការគណៈរដ្ឋមន្រ្តី

៦- ក្រសួងអប់រំ យុវជន និងកីឡា

៧- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៨- ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

៩- ក្រសួង ព័ត៌មាន

១០- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

១១- ក្រសួង ធនធានទឹក និងឧតុនិយម

១២- ក្រសួង យុត្តិធម៌

១៣- ទីចាត់ការគយ និងរដ្ឋាករ

១៤- ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ

១៥- នាយកដ្ឋាន ពន្ធដារ

១៦- ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

១៧- ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល

១៨- ក្រសួង កិច្ចការនារី

១៩- ក្រសួង ទេសចរណ៍

២០- ធនាគារជាតិ នៃកម្ពុជា

២១- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

២២- រដ្ឋលេខាធិការដ្ឋាន ក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា

២៣- ក្រសួង សុខាភិបាល

២៤- ក្រសួងការពារជាតិ

២៥- ក្រសួង សាធារណៈការ និងដឹកជញ្ជូន

២៦- ក្រសួង ធម្មការ និងសាសនា

២៧- រដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល

អវត្តមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ , ក្រសួងពាណិជ្ជកម្ម , ក្រសួងបរិស្ថាន និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **សន ស៊ីថន** អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិបានមានប្រសាសថាៈវិទ្យាស្ថានជាតិស្ថិតិបាន រៀបចំច្បាប់ស្តីពីស្ថិតិ និង អនុក្រិត្យ ស្តីពីតួនាទីនិងការរៀបចំ ចុះហត្ថលេខាដោយ នាយរដ្ឋមន្ត្រី កាលពីថ្ងៃទី២៧ ខែ មករា ឆ្នាំ ២០០៧។ អនុក្រត្យនេះ បានបញ្ជាក់ពីយន្តការសំរបសំរួល សំរាប់ប្រពន្ធ័ស្ថិតិជាតិ រួមបញ្ចូលទាំង ក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិតិ និងគណៈកម្មាធិការសំរបសំរួលស្ថិតិស្ថិតិ ។ ភារកិច្ចរបស់គណៈកម្មាធិការសំរបសំរួលស្ថិតិបានចែងថា : ត្រូវមានកិច្ចប្រជុំ ៤ដង ក្នុងមួយឆ្នាំដើម្បីពិភាក្សាផែនការ ។ នៅថ្ងៃនេះមានអ្នកចូលរួមគ្រប់គ្រាន់ដើម្បី ដំណើរការកិច្ចប្រជុំឯកភាពគ្នាយ៉ាងហោចណាស់ក៏មានសមាជិលវត្តមាន១៧រូប ដើម្បីកិច្ចប្រជុំដំណើរការបាន ។ តំរូវការដើម្បីយល់ដឹង និងផ្សព្វផ្សាយពតិមានអំពីច្បាប់ស្ថិតិត្រូវបានគេគូសបញ្ជាក់ដើម្បីធានាថា ប្រជាជនមានសុឆន្ទៈ ដើម្បីឆ្លើយនូវសំនួរដែលបានផ្តល់ជូនទៅពួកគេដោយមន្ត្រីស្ថិតិ។

ឯកឧត្តមបានបន្តថា ការអនុម័ត្រផែនការមេស្ថិតិពីរដ្ឋាភិបាល គឺជាការសំខាន់ក្នុងការធានាគាំទ្រពីរដ្ឋាភិបាលកម្ពុជាទាំងអ្នកផ្តល់ជំនួយ ។ មានការកែសំរួលថ្មី នៃផែមការមេស្ថិតិ ដែលបានផលិតចេញនៅ ខែ សីហា ឆ្នាំ ២០០៦ ។ ផែនការមេស្ថិតិនឹងដាក់បញ្ជូនទៅក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិតិដើម្បីអនុម័ត្ត ហើយនឹងដាក់បញ្ចូលទៅនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា ។

នេះគឺជាដំណើរការសំខាន់ក្នុងការតស៊ូមតិ ដើម្បីឱ្យរដ្ឋាភិបាលគាំទ្រនូវធនធានឱ្យធានាថា ការងារសំរបសំរួល ស្ថិតិគឺមានប្រសិទ្ធភាព។

លោក **Zia Abassi** បានមានប្រសាសថា ប្រពន្ធ័ស្ថិតិវិមជ្ឈការ នៅប្រទេសកម្ពុជា។ ដូច្នេះ ដើម្បីធានានូវការផ្គត់-ផ្គង់ឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលាពីស្ថិតិរដ្ឋាភិបាល ការសំខាន់នោះគឺមានកិច្ចសហការលវវាងវិទ្យាស្ថានជាតិស្ថិតិ និងក្រសួងពាក់ពន្ធ័ខាងផ្នែកស្ថិតិ ។ វិទ្យាស្ថានជាតិស្ថិតិមានអាណត្តសំរាប់ប្រៀបធៀបមើលរាល់ស្ថិតិសេដ្ឋកិច្ចសង្គមកិច្ច បោះពុម្ពនៅសៀវភៅស្ថិតិតាមឆ្នាំ ។ គណនេយ្យជាតិដែលវាស់វែងកំណើន GDP ចាំបាច់ឱ្យមានស្ថិតិពីតាមបណ្តាក្រសួង ពាក់ពន្ធ័ដើម្បីផលិតចេញនូវទិន្ន័យដូចគ្នាជាក់លាក់ដើម្បីឱ្យមានការសំរបសំរួលនិងកិច្ចសហការប្រកបដោយប្រសិទ្ធភាព។

បណ្តាក្រសួងដ៏ទៃទៀត ដូចជាកិច្ចនារី និងក្រសួងសង្គកិច្ចនិងការងារ និង អប់រំត្រូវការឱ្យមានលទ្ធភាពខាង ស្ថិតិទៅដល់វិទ្យាស្ថានជាតិស្ថិតិនូវពតិមានគោលនយោខាយរបស់ខ្លួន ។ ផែនការមេស្ថិតិព្យាយាមធានាថាមានថវិការ គ្រប់គ្រាន់សំរាប់ផលិតចេញនូវគុណភាពស្ថិតិដោយវិទ្យាស្ថានជាតិស្ថិតិ និងតាមផ្នែកស្ថិតិរបស់បណ្តាក្រសួងពាក់ពន្ធ័ ។ តួនាទីរបស់គណៈកម្មាធិការក្រុមប្រឹក្សាស្ថិតិគឺអនុវត្តផែនការមេស្ថិតិ គឺថាធានានូវថវិការគ្រប់គ្រាន់ និងទាន់ពេលវេលា និងមិនជាន់ការងារគ្នាក្នុងការប្រមូលទិន្ន័យ ហើយគណៈកម្មាធិការក្រុមប្រឹក្សាស្ថិតិក៏និងផ្តល់ផងដែរនូវវេទិការសំរាប់ប្រកាសនូវការប្រមូលទិន្ន័យថ្មី អញ្ជើងមានកាលានុវត្តភាពសំរាប់ដាក់បញ្ចូលទៅក្នុង ការចាត់ចែង នូវរូភាពឧមករណ៏ការប្រមូលទិន្ន័យពីបណ្តាក្រសួងពាក់ពន្ធ័។

ក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិតិ (SAC) គឺជាអង្គភាពក៏រិតខ្ពស់ដោយមានតំណាងត្រឹមរដ្ឋលេខាធិការ រឺក៏អនុរដ្ឋលេខាតាមបណ្តាក្រសួងពាក់ពន្ធ័ អាចធានាថាមានការគាំទ្រគោលនយោបាយអនុវត្ត របស់អនុសាសន៏ពីគណកម្មាធិការក្រុមប្រឹក្សាស្ថិតិប្រសិនណាត្រូវបានគេអនុម័ត្ត ។ តំរូវការសំរាប់ចំណាត់ថ្នាក់ស្តង់ដាទិន្ន័យ ។

មានគ្រោងការមួយគឺចំណាត់ថ្នាក់ស្តង់ដាសេដ្ឋកិច្ចះអន្តរជាតិ (ISIC)។ ធនាគាជាតិនៃកម្ពុជា បច្ចុប្បន្នប្រើប្រាស់ចំណាត់ថ្នាក់ផ្ទាល់របស់ខ្លួនគេ ហើយក្រសួងឧស្សាហាកម្ម រ៉ែនិងថាមពលប្រើប្រាស់ (ISIC) revisions three សើរីលើកទីបី ក៏ប៉ុន្តែគួរប្រើ (ISIC) revisions four សើរីលើកទី៤ ជាស្តង់ដាទូទៅ ចាំបាច់ត្រូវគេអនុម័ត្តដើម្បីធានាថា អាចប្រើទិន្ន័យមកពីបណ្តាក្រសួងផ្សេងៗ និងដែលអាចប្រៀបធៀបបាន។ បង្កើនច្រកដល់ទិន្ន័យរដ្ឋាភិបាល តាមរយៈការផ្សព្វផ្សាយដែលត្រូវបានគេត្រិះរិះថាជាការសំខាន់ និងតាម Website។ ការបង្កើនឡើងនូវឧបករណ៏សំខាន់ៗ តាម website ផ្ទាល់របស់សមុីក្រសួង រឺក៏តាម website របស៉វិទ្យាស្ថាជាតិស្ថិតិ។

មតិរបស់លោក **Dr Andrew Pinney** បានបញ្ជាក់ពីសារៈសំខាន់នៃការរៀបចំ ទំនាក់ទំនងដែល មាន២ច្រក ជាមួយនឹងផ្នែកស្ថិតិតាមបណ្តាក្រសួងពាក់ពន្ធ័ ហើយមិនមែនតែវិទ្យាស្ថានជាតិស្ថិតិទេដែលតំរូវការនូទិន្ន័យ ។ វិទ្យាស្ថានជាតិស្ថិតិចង់ឱ្យមានលទ្ធភាព ដើម្បីផ្តល់នូវតំលៃបន្ថែមចំពោះទិន្ន័យដែលមានតាមរយៈឱ្យមានស្តង់ដាទិន្ន័យស៊ីសង្វាក់គ្នា និងការពិពណ៌នាពី Metaddata និងការផ្ទុកនូវការប្រមូលស្ថិតិផ្លូវការនៅវិទ្យាស្ថានជាតិស្ថិតិដែលជាកន្លែងទុកដាក់ទិន្ន័យដោយកែលំអរនូវលទ្ធភាពចំពោះទិន្ន័យនេះតាមរយៈ **(Intranet)** ។ ឃ្លាំងផ្ទុកទិន្ន័យស្នូលផ្តល់គ្រប់លទ្ធភាពដូចគ្នា និងកំណែ

ស្តង់ដានៃទិន្នន័យ និងបង្ការនូវកំហែរ ផ្សេងចំពោះការរៀបចំទិន្នន័យហួសកាលសម័យ។ កំរងសំណួរខានបង្ហាញ បន្ទាប់មកទៀត ដោយ គីម ណេត គឺត្រូវបានគេចាត់ តាំងឱ្យ ដើម្បី បញ្ជាក់ពីរាល់ផ្នែកស្ថិតិនៅតាមបណ្តាក្រសួងពាក់ពន្ធ័ដែលខានចុះបញ្ជី ទាំងក៏រិតថ្នាក់បុគ្គលិក និងលក្ខណសម្បត្តិ ព្រមទាំងយកសារពើពន្ធនៃរាល់សូរចណាកដែលបានប្រមូលនូវពេលថ្មី១នេះ ហើយ ទាំងនោះគឺត្រូវបានគេគ្រោងឡើង។ ដូច្នេះ អង្កេតត្រូវបានគេវិភាគ កម្មវិធីសំរាប់ផ្គត់ផ្គង់ដើម្បីជ្រើសរើសផ្នែកស្ថិតិតាមបណ្តា ក្រសួងពាក់ពន្ធ័ នឹងត្រូវទទួលយកបណ្តោសន្ទ នូវកុំព្យូទ័រ ដើម្បីតភ្ជាប់ជាមួយ **Intranet** មកកាន់ វិទ្យាស្ថានជាតិស្ថិតិ និងបណ្តុបណ្តាលតាមវិធីវិភាគ និង software សំរាប់គូផែនទី។ លទ្ធផលនៃការអង្កេតតាមផ្នែកស្ថិតិតាមបណ្តាក្រសួងពាក់ពន្ធ័ នឹងបងាញនូវកិច្ចប្រជុំ គណកម្មាធិការក្រុម ប្រឹក្សាស្ថិតិលើកក្រោយ។ យុទ្ធសាស្រ្តមួយនៃយុទ្ធសាស្រ្តជាច្រើន ក្នុងការកែលំអ លទ្ធភាពឃ្លាំងផ្ទុកទិន្នន័យ។ គឺបានកំពុងតែស្នើ ប៉ុន្តែមិនទាន់បានអនុម័តនៅឡើយ ដើម្បីទិញ software សំរាប់ដំណើការ វិធីវិភាគតាមប្រពន្ធ័អ៊ិនទ័ណិត SuperSTAR សំរាប់ដែលនឹងមកបងាញនៅថ្ងៃទី ៦ ខែ មិនា ម៉ោង៩ វិទ្យាស្ថានជាតិស្ថិតិ ដែលអស់លោកអ្នកនិងមកចូលរួមច្រើន។

មតិបន្ថែមរបស់ ឯកឧត្តម **សន ស៊ីថន** អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិមានប្រសាសថាៈ ប្រទេសដូចជាប្រទេសកម្ពុជាយើង ផែនការមេស្ថិតិ គឺជាឯកសារយុទ្ធ សាស្រ្តគន្លឹះ សំរាប់ការអភិវឌ្ឍន៍ប្រពន្ធ័ស្ថិតិជាតិ។ ដើម្បីកែលំអរនូវសម្បជញ្ញៈ នៃតួនាទីរបស់ប្រពន្ធ័ស្ថិតិជាតិ ដូចដែលមានជាសង្ខេបនៅក្នុងព្រឹត្តប័ត្រដែលបានបោះផ្សាយ ចំណុចសំខាន់នៃអនុក្រិត្យថ្មីកំពុង ដំណើរការ ដើម្បីផលិតនូវព្រឹត្តបត្រ័សំរាប់ គណកម្មាធិការ ក្រុមប្រឹក្សាស្ថិតិ ( SCC) និងក្រុមប្រឹក្សាពិគ្រោះ យោបល់ស្ថិតិ ( SAC)។ មានវិការដ្ឋានផែនការជាច្រើន ដើម្បីបើកសាវនការ និងធ្វើសិក្ខាសាលាទៅលើផែនការមេស្ថិតិកម្ពុជា ដើម្បីអញ្ជើញ អ្នកចូលរួមអន្តរជាតិពីធនាគាពិភពលោក និងផ្នែកស្ថិតិអង្គាសហប្រជាជាតិ (UNSD)។ (UNSD) កំណត់ស្តង់ដាស្ថិតិ ហើយ បច្ចុប្បន្ននេះ ដឹកនាំដោយអតីតនាយកស្ថិតិប្រទេសសិងពួរ ប្រហែលជាខ្លួនគាត់និងមកចូលរួម។ អគ្គនាយកនឹងទៅទស្សនកិច្ច ទីក្រុងញ៉ូយក សហរដ្ឋអាមេរិកនៅសប្តាហ៏ក្រោយ ដើម្បីឡើងបងាញ ឯកសារស្តីពីស្ថិតិមុននិងក្រោយរបបខ្មែរក្រហមនៅកម្ពុជា នៅឯសន្និសិទ្ធថ្នាក់ដឹកនាំស្ថិតិអន្តរជាតិ។ សូចនាករមួយក្នុងបណ្តាចំណោមសូចនាករជាច្រើន នៃតឹកតាងការអភិវឌ្ឍន៍របស់ ប្រពន្ធ័ស្ថិតិកម្ពុជា គឺកម្ពុជាមានលទ្ធភាពផលិតចេញនូវគណៈនេយ្យជាតិរាល់៣ខែ ដែលប្រហែល ជា៥០ប្រទេសបច្ចុប្បន្ន គ្រប់គ្រង។ ហិរញ្ញវត្ថុរដ្ឋាភិបាលសំរាប់ស្ថិតិ គឺ១.២ លានដុល្លា ប៉ុន្តែនេះនឹងកើនដល់ ២លានដុល្លា នៅឆ្នាំ ២០១០ ជិតស្មើនិង ចំនួនពីអ្នកផ្តល់ជំនួយអន្តរជាតិ។ ប្រការនេះ គឺជាថវិការទាំងមូលរបស់ប្រពន្ធ័ស្ថិតិ ដែលរាប់បញ្ចូលទាំងថវិកាសំរាប់ផ្នែកស្ថិតិ របស់ក្រសួងពាក់ពន្ធ័។ រដ្ឋាភិបាលនឹងគាំទ្រជំរឿនប្រជាសាស្រ្តឆ្នាំ ២០០៨ ដោយផ្តល់រថយន្ត៣០គ្រឿង និងម៉ូតូ ហើយនិងការ គាំទ្រផ្សេងទៀតដែលមានតំលៃ ៧០០ ០០០ដុល្លារ។ អ្នកផ្តល់ជំនួយកំពុងផ្តល់ឱ្យ៤.៧លានដុល្លារ ហើយក្រៅពីនោះថវិការមក ពីរដ្ឋាភិបាល ថវិកាសរុបទាំងអស់៦លានដុល្លារ សំរាប់ធ្វើជំរឿនឆ្នាំ២០០៨។ ទាំងអស់នេះគឺជាសូចនាករជាច្រើនរបស់ប្រទេស កម្ពុជាគឺកំពុងបង្កើនការងារស្ថិតិនិងលទ្ធភាពដើម្បីប្តេជ្ញាផ្តល់ថវិការ។

ផែនការមេស្ថិតិ បានគូសបញ្ជាក់ពីភាពទាន់ពេលវេលា និងកាលវិភាគនៃជំរឿននិងអង្កេតដែលជាអាទិភាព។ ជាគំនិតគឺថា យុគភាពដំបូងទាំងនេះគួរតែទទួលបានថវិការពេញលេញជាអាទិភាពមួយ។ ខណៈនេះផងដែរ មិនគួររារាំងការអនុវត្តនីការធ្វើអង្កេតនោះទេ គួរតែទទួលស្គាល់អ្នកផ្តល់ជំនួយ លើការផ្តល់អាទិភាពដំបូងនូវកិច្ចការប្រមូលទិន្នន័យ។

ស្ថានការណ៍ នៃជំរឿនកសិកម្មគឺមិនច្បាស់លាស់ ហើយអត់មានអ្នកតំណាងមកពីក្រសួងកសិកម្ម មកចូលរួមកិច្ចប្រជុំនៅថ្ងៃនេះទេ។ ចំពោះការស្ថាបនាធ្វើជំរឿននិងអង្កេត មានផែនការនិងកម្មវិធីការងារដោយមានការគាំទ្រពី JICA ។

លោក **Zia Abassi** បានធ្វើការបញ្ជាក់ ពីផែនការមេស្ថិតិនៅជំហានបន្ទាប់ នៅសិក្ខាសាលាអន្តរជាតិ ស្តីពីផែនការមេស្ថិតិ និងបន្ទាប់មកគណៈកម្មាធិការពិគ្រោះយោបល់ស្ថិតិ និងអនុម័តលើផែនការមេស្ថិតិ និងដាក់ឆ្លងទៅក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី ដើម្បីសុំការឯកភាពពីនាយករដ្ឋមន្ត្រី ហើយបន្ទាប់មកបង្ហាញនៅសិក្ខាសាលាស្តីពីផែនការមេស្ថិតិ។ នឹងមានកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់ស្ថិតិឆ្លងសារលិខិតទៅគណៈកម្មាធិការ ហើយបន្ទាប់មកទៅកាន់វេទិការកិច្ចសហប្រតិបត្តការការអភិវឌ្ឍន៍កម្ពុជា (CDCF) ដែលបានរំពឹងថាប្រហែលជានៅខែមិថុនាឆ្នាំនេះ។

**សូមអរគុណ**